ជំពូកទី ៣

Draft

ជំពូកទី ៣: ការពិពណ៌នាគំរោង

៣.១ ប្រវត្តិគំរោង

គំរោងមរកតមានឈ្មោះដើមជាគំរោងអភិវឌ្ឍន៍កោះពស់ និងឆ្នេរហាវ៉ៃ ដែលវិនិយោគទុនដោយក្រុមហ៊ុន **កោះពស់ (ខេមបូឌា) អ៊ីនវេសមេនត្រ្ពេប អ៊ីលធីឌី** យោងតាមកិច្ចសន្យាជួលកោះពស់ និងឆ្នេរហាវ៉ៃ ក្នុងរយៈពេល៩៩ឆ្នាំ ពីរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៦ និងកិច្ចសន្យាបន្ថែមស្តីពី ការកែសំរួលខ្លឹមសារក្នុងកិច្ចសន្យាជួល កោះពស់ និងដីឆ្នេរហាវ៉ៃ ក្នុងក្រុងព្រះសីហនុ ពាក់ព័ន្ធនឹងការប្តូរទីតាំងសាងសង់គល់ស្ពានតភ្ជាប់ផ្នែកដីគោកទៅកោះពស់ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនកោះពស់ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៧ (មើលឧបសម្ព័ន្ធ ២ឃ) ។

កោះពស់ (ខេមបូឌា) អ៊ីនវេសមេនត្រ្ពេប អ៊ីលធីឌី ជាក្រុមហ៊ុនវិនិយោគមួយមកពីប្រទេសរ៉ូស្ស៊ី។ ក្រុមហ៊ុនមានការិយាល័យនៅកម្ពុជា ដែលមានអាសយដ្ឋាន ផ្ទះលេខ ០៦៣ ផ្លូវឯករាជ្យ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ នាយកគំរោងនៅកម្ពុជាគឺ លោក អ្នាន់ដ្រូ ហាលទ្យូរីន Mr. ANDREW HALTURIN (Project Director) ។

៣.២ ទីតាំងគំរោង

គំរោងមរកត មានទីតាំងនៅក្នុងភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ (មើលរូបភាព ៣.២-១) ។ តំបន់គំរោងនេះមានចំងាយប្រមាណ ២៣០គម ពីរាជធានីភ្នំពេញ ហើយអាចធ្វើដំណើរមកដល់បានតាមផ្លូវជាតិ លេខ៤ ឬផ្លូវដែកខ្សែភ្នំពេញ-ក្រុងព្រះសីហនុ។ **គំរោងមរកត** មានសមាសធាតុធំៗបីផ្នែកគឺ ផ្នែកលើកោះពស់ ផ្នែកឆ្នេរហាវ៉ៃ និងស្ពានកោះពស់ ។

កោះពស់គឺជា កោះមួយតូចស្ថិតនៅក្នុងសង្កាត់លេខ៣ ក្បែរដីគោកនិងនៅទល់មុខសណ្ឋាគារឯករាជ្យ (ឈ្មោះចាស់ ហៅថា សណ្ឋាគារប្រាំពីរជាន់) និងឆ្នេរកោះពស់ (ឈ្មោះចាស់ ហៅថា ឆ្នេរហាវ៉ៃ) ។

ឆ្នេរកោះពស់ ឬឆ្នេរហាវ៉ៃ ស្ថិតនៅចន្លោះសណ្ឋាគារឯករាជ្យ និងកំពង់ផែកំពង់សោម ដែលជាកន្លែងមានចំណាប់អារម្មណ៍ពីភ្ញៀវទេសចរណ៍លើឆ្នេរដ៏ស្រស់ស្អាតនៅទីនេះ ។

ស្ពានកោះពស់ ស្ថិតនៅក្បែរភោជនីយដ្ឋានកោះពស់ខាងដីគោក ហើយភ្ជាប់ទៅកោះពស់ ។

Draft


364000
368000
332000
1188000
1184000
1180000
1176000
1172000
1168000
80
76
84
66
62
64
88
86
ស្ពានកោះពាស
Data Sources
JICA dataset 2002
Projectoin: UTM, Zone 48 N
Ellipsoid: Everest 1830
Datum: India 1960
Unite: Meter
4

Draft

៣.៣ ប្រភេទ និងទំហំ

គំរោងមរកត គឺជាគំរោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ចំរុះសម័យទំនើបមួយ ដែលរួមមានសមាសធាតុសំខាន់ៗបីគឺ ការសាងសង់ស្ពានកោះពស់ ការអភិវឌ្ឍលើកោះពស់ និងការអភិវឌ្ឍលើឆ្នេរបាវៀ សូមមើលរូបភាព ៣.៣-១ ។ ស្ពានកោះពស់នឹងតភ្ជាប់ដីគោកវាប់ទាំងឆ្នេរបាវៀនៃក្រុងព្រះសីហនុទៅកាន់កោះពស់ ។ គំរោងនេះជារមណីយដ្ឋានចំរុះមានទំហំធំមួយនៅក្នុងខេត្តព្រះសីហនុ ។



រូបភាព ៣.៣-១: សមាភាពសំខាន់ទាំងបីនៃគំរោងមរកត

គំរោងនេះជាការវិនិយោគទុនឯកជនមួយដែលមាន**រយៈពេល៩៩ឆ្នាំ** រាប់ទាំងពេលវេលាសាងសង់ និងប្រតិបត្តិការ យោងតាមកិច្ចសន្យាជួលរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនកោះពស់(ខេមបូឌា) អ៊ីនវេសមេនគ្រុបអ៊ីលធីឌី។ ដូចនេះគំរោងនេះជាប្រភេទគំរោង សាងសង់ ប្រតិបត្តិការ និងផ្ទេរ ហៅកាត់ជាភាសាអង់គ្លេសថា **"BOT"** ហើយដែលមានទុនវិនិយោគសរុបប្រមាណជា **៤៤0 លានដុល្លាអាមេរិកកាង** ។

ទំហំនៃសមាសធាតុលំអិតគំរោងមានព័ណ៌នាដូចខាងក្រោមនេះ:-

៣.៣.១ ការសាងសង់ស្ពានកោះពស់

ស្ពានកោះពស់គឺជាប្រភេទស្ពានបេតុង ដែលមានប្រវែង ៩០០ម៉ែត្រ ទទឹង ១២ម៉ែត្រ និងមានកំពស់ពីផ្ទៃទឹកសមុទ្រ ៣២ម៉ែត្រ។ ផ្លូវក្រាលកៅស៊ូបីទុមីណាដែលភ្ជាប់ចុងសងខាងរបស់ស្ពាន ប្រវែងរាប់រយម៉ែត្រក៏រាប់បញ្ចូលនៅក្នុងសំណង់ស្ពាននេះផងដែរ។

ស្ពាននេះនឹងសាងសង់ជាមួយនឹងផ្លូវមេ និងផ្លូវជំនួយទាំងសងខាង ដោយយោងទៅតាមតំរូវការចរាចរណ៍។ មើលចំពីមុខ ស្ពាននេះមានរាងជាអក្ស "T"។ តួស្ពាន ជាថ្មីមបេតុងបន្តគ្នា (១១០ម + ២២០ម + ១១០ម) មានន័យថា នៅត្រង់ចន្លោះកណ្តាលស្ពានមានចំងាយ ២២០ម ពីសសរមួយទៅសសរមួយទៀត ហើយប្រឡោះបន្ទាប់មានគំលាតពីសសរមួយទៅសសរមួយគឺ ១១០ម មើលរូបភាព ៣.៣.១-១ និងរូបភាព ៣.៣.១-២ បង្ហាញពីគ្រោងបួងស្ពានកោះពស់។



រូបភាព ៣.៣.១-១: ការមើលឃើញជាទូទៅនៃស្ពានកោះពស់

ក្រៅពីសំណង់ស្ពាន មានសមាសភាពមួយចំនួនទៀតដូចជា អាគាររដ្ឋបាល (ការិយាល័យរដ្ឋបាល និងបន្ទប់ទទួលភ្ញៀវ) ដែលមានផ្ទៃក្រឡា ៨០០ម^{២} ស្ថិតនៅចំងាយ៣០០ម ពីស្ពាន និងជំរុំកម្មករដែលមានផ្ទៃក្រឡាសរុប ១០០០០ម^{២} នៅលើដីជួលជាប់មាត់សមុទ្រ។ តំបន់សាងសង់បណ្តោះអាសន្ន និង គ្រឿងបរិក្ខាសំណង់នឹងត្រូវទុកដាក់នៅមាត់សមុទ្រ។ មានទីលានបីកន្លែងនៅខាងដីគោក និងពីរកន្លែងនៅលើដីកោះ ហើយរបារស្ទូរដែកនឹងត្រូវតំឡើងតាមបណ្តោយអ័ក្សរបស់ស្ពានរហូតដល់កោះ លើកលែងតែប្រលោះកណ្តាលប្រវែង ២០០ម៉ែត្រ ដែលទុកឱ្យនាវា និងទូនេសាទឆ្លងកាត់បាន។ ប្រព័ន្ធលាយស៊ីម៉ង់ត៍មួយនឹងត្រូវតំឡើងនៅជិតការដ្ឋានសាងសង់នៅលើទីលានខាងដីគោក។


Notes:
1. All dimensions are in millimeters.

ប្រព័ន្ធនេះ នឹងបំពាក់ដោយម៉ាស៊ីនផ្ត់ផ្ត្ងស្ម័យប្រវត្តិ 2 **JS750-forced mixers** ឧបករណ៍ ច្រកដោយមេកានិចស្ពប់បូមផ្ទេរ ។ល។ ឃ្លាំងផ្ទុកស៊ីម៉ង់ត៍ និងកន្លែងតរថ្ត្រូសនឹងមានរៀបចំតាមរបៀប ដោយមានប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបញ្ជេញផ្សែងយ៉ាងគ្រប់គ្រាន់ ។

ផ្ទៃសាងសង់ស្ពានកោះពស់សរុប គឺប្រមាណជា ៥០ លានដុល្លាអាមេរិកកាំង ។

៣.៣.២ ការអភិវឌ្ឍលើឆ្នេរហាវ៉ៃ

ការអភិវឌ្ឍឆ្នេរហាវ៉ៃ មានសមាភាពចំនួន១០ ដែលមានទំហំផ្ទៃដី និងផ្ទៃអាគារច្បាស់លាស់ដូចមានរៀបរាប់ក្នុងតារាង ៣.៣.២-១ ។ ការរៀបចំប្លង់សមាសភាពនីមួយៗនៃការអភិវឌ្ឍឆ្នេរហាវ៉ៃ មានបង្ហាញនៅរូបភាព ៣.៣.២-១ ។ តំលៃសាងសង់សំរាប់ការអភិវឌ្ឍឆ្នេរហាវ៉ៃសរុបប្រមាណជា ៩០ លានដុល្លាអាមេរិកកាំង ។

តារាង ៣.៣.២-១: សមាភាពទាំង១០ នៃការអភិវឌ្ឍឆ្នេរហាវ៉ៃ

ល.រ	បរិយាយ	ផ្ទៃដី ម^{២}	ផ្ទៃអាគារ ម^{២}
១	សណ្ឋាគារ និងលំនៅដ្ឋានខ្ពស់ៗ	៣ ០៨៨	២ ៧៥០
២	អាគារពាណិជ្ជកម្ម រួមមានចំណតរថយន្តក្រោមដីពីរជាន់	២ ០០០	១ ០០០
៣	អាគារពាណិជ្ជកម្ម ដែលមានចំណតរថយន្ត និងយានដ្ឋាន	៤ ០០០	១ ៧៥០
៤	អាគារការិយាល័យធុនមធ្យម	៣ ០០០	៣០០
៥	បន្ទប់តាំងរូបភាពតូចៗ	៥០០	៥០០
៦	ផ្ទះវិទ្យាមានអាងបែលទឹកឯកជន	៨ ០០០	២៥០០
៧	ក្លឹបកំសាន្ត	៥០០	៤០០
៨	ភោជនីយដ្ឋានអាហារសមុទ្រ	៥០០	៤០០
៩	កន្លែងទស្សនាផ្ទៃលិច	៧០០	៧០០
១០	កន្លែង/បន្ទប់ SPA	៥០០	៥០០
	ផ្ទៃសរុប	**២២ ៧៨៨**	**១០ ៨០០**

Draft



រូបភាព ៣.៣.២-១: ការរៀបចំប្លង់សមាសភាពនៃការអភិវឌ្ឍលើឆ្នេរហាវ៉ៃ



រូបភាព ៣.៣.២-២: ការមើលឃើញពីក្រោយនៃការអភិវឌ្ឍផ្នែករបាវ

៣.៣.៣ ការអភិវឌ្ឍលើកោះពស់

ការអភិវឌ្ឍលើកោះពស់រួមមាន ១៤តំបន់ ដែលមានតំបាំផ្ទៃដី និងផ្ទៃអាគារច្បាស់លាស់ ដូចមានរៀបរាប់ក្នុងតារាង ៣.៣.៣-១ ។ មានកន្លែងសេវាកម្មបំរើឱ្យសាធារណៈ និងទេសចរណ៍ជាច្រើនកន្លែង ត្រូវបានរៀបចំប្លង់នៅក្នុងតំបន់នីមួយៗ ដូចជា សាលារៀន គិលានដ្ឋាន វត្តអារាម ស្ថានីយ៍ប៉ូលីស សណ្ឋាគារ ភោជនីយដ្ឋាន មណ្ឌលពាណិជ្ជកម្ម ឬ ហាងលក់ទំនិញ ។ល។ ការរៀបចំប្លង់ទូទៅនៃការអភិវឌ្ឍលើកោះពស់មានបង្ហាញជូននៅក្នុងរូបភាព ៣.៣.៣-១ ។

តារាង ៣.៣.៣-១: តំបន់ទាំង ១៤ នៃការអភិវឌ្ឍនៅលើកោះពស់

ល.រ	បរិយាយ	ផ្ទៃដី ម^{២}	ផ្ទៃសាងសង់ ម^{២}
១	**ស្ពាន**		**១១.២៥០**
២	**តំបន់ឆ្នេរខ្សាច់**	**៥៣.៨០០**	**១៤.៧៥០**
២.១	ទីស្នាក់ការរថយន្តជួយសង្គ្រោះ	៣០០	១០០
២.២	ប៉ម‌មើលឆ្នេរ	៣០០	២០០
២.៣	កន្លែងរក្សាទុកកៅអី និងសំភារៈសំអាតឆ្នេរ	១.០០០	៨០០
២.៤	កន្លែងដាក់ធ‌ម្ម‌ត្រ-ពុ, បន្ទប់តូច៨, បន្ទប់ទឹក	២០.០០០	៦.២០០
២.៥	បន្ទប់ងូតទឹកសាប	៦០០	៨០
២.៦	កន្លែងបាល/អាំងថ្ម	២.០០០	១.២០០
២.៧	បឹងហ្គាឡូនៅលើទឹកចំនួន២៤	២៩.៦០០	៦.២១០
៣	**តំបន់កំសាន្តក្បែរឆ្នេរខ្សាច់**	**៩៩.៨០០**	**៥៤.៩០០**
៣.១	សណ្ឋាគារជួរទីមួយ	៤២.០៥០	២០.២០០
៣.២	ឧទ្យាន	២៤.៦៥០	២២.៩៥០
៣.៣	ភោជនីយដ្ឋាន	៦០០	២០០
៣.៤	ទីលានបាល់ទះ កន្លែងក្មេងលេង កន្លែងហាត់ប្រាណ	៤០០០	៣.០០០
៣.៥	បឹងហ្គាឡូតំលៃខ្ពស់នៅលើឆ្នេរ ចំនួន ២០-៣០	២៨.៥០០	៨.៥៥០
៤	**តំបន់បំរើឱ្យសេវាកម្មសាធារណៈ**	**១០៦.៦០០**	**២៩.១៩៨**
៤.១	សណ្ឋាគារជួរទីពីរ	៥៣.០០០	១៦.៧៤៨
៤.២	កន្លែងប្រគុំតន្ត្រី ក្លឹបឌីស្គូ រោងភាពយន្ត		

Draft

ល.រ	បរិយាយ	ផ្ទៃដី ម^{2}	ផ្ទៃសាងសង់ ម^{2}
៤.៣	វត្តអារាម និងសារមន្ទីរវប្បធម៌	៥៣.៦០០	១២.៤៥០
៥	**តំបន់លំនៅដ្ឋានកំរិតខ្ពស់**	**៥៨.៤០០**	**១៩.០០០**
៥.១	សណ្ឋាគារ	១២.១០០	៣.២០០
៥.២	មជ្ឈមណ្ឌលពាណិជ្ជកម្ម	១៥.៧០០	៩.០០០
៥.៣	ផ្ទះល្វែង	១០.៦០០	៥.១០០
៥.៤	ការិយាល័យ និងមណ្ឌលរដ្ឋបាល	២០.០០០	១.៧០០
៦	**ទួលខ្ពស់មើលឃើញជុំវិញកោះ និងមានរូបបដិមា**	**១០.៣០០**	**៤៩០**
៦.១	រូបបដិមាព្រះពុទ្ធមួយអង្គ	២.០០០	២០
៦.២	ព្រះវិហារតូចៗ	២.៣០០	២០០
៦.៣	ចំណតរថយន្ត	២.០០០	៥០
៦.៤	រង្គសាល/បារ	២.០០០	១៥០
៦.៥	បាងលក់វត្ថុអនុស្សាវរីយ៍	២.០០០	៧០
៧	**តំបន់ក្លឹបល្បែង**	**៦២.៨០០**	**១៨.៥០០**
៧.១	អាគារកាស៊ីណូ សណ្ឋាគារ VIP ភោជនីយដ្ឋាន កន្លែងចតរថយន្ត	៣៨.៩០០	៥.០០០
៧.២	កន្លែងបាញ់ទឹក	៥.០០០	៤០០
៧.៣	ឧទ្យាន	១៨.០០០	១៣.០០០
៧.៤	ស្ថានីយ៍ប៉ូលីស	៩០០	១០០
៨	**មជ្ឈមណ្ឌលលក់ទំនិញ**	**៨៨.៩០០**	**៤៤.១៧០**
៨.១	បាងលក់ទំនិញ	២៧.០០០	៨.៣២០
៨.២	តំបន់ទំនិញរួចពន្ធ	១៦.៣០០	៦.០៥០
៨.៣	ផ្សារទំនើប ដែលមានបាងកាហ្វេ	២០.០០០	៩.២០០
៨.៤	កន្លែងចតរថយន្ត	១០.០០០	១០.០០០
៨.៥	ផ្សាររាត្រី/ផ្សារលក់ផលិតផលក្នុងស្រុក	១៥.០០០	១០.០០០
៨.៦	កន្លែងជួលកង់ ម៉ូតូ	៦០០	៦០០
៩	**តំបន់លំនៅដ្ឋាន**	**១០៩.៨០០**	**៣៧.៩៤០**

Draft

ល.រ	បរិយាយ	ផ្ទៃដី ម^{2}	ផ្ទៃសាងសង់ ម^{2}
៩.១	សំណង់ផ្ទះល្វែង	៦១.១០០	២៨.០០០
៩.២	ពហុព្យាបាល	១៤.៣០០	១.៨៦០
៩.៣	សាលារៀន	២០.០០០	២.២០០
៩.៤	ការិយាល័យ	៥.០០០	៩៨០
៩.៥	ស្ថានីយ៍ប៉ូលីស	៥.០០០	៥០០
៩.៦	កន្លែងចតរថយន្ត	៤.៤០០	៤.៤០០
១០	**តំបន់លំនៅដ្ឋានក្នុងធម្មជាតិ**	**៦៣.២០០**	**៩៩..៥០០**
១០.១	កន្លែងវាយកូនហ្គោល	៨២.៧០០	៨២..៧០០
១០.២	កន្លែង SPA	១០.០០០	៣.៤០០
១០.៣	កន្លែងគ្រឿងចំលាក់អំពីថ្ម	៦.០០០	១.៤០០
១០.៤	ផ្ទះវីឡាឯកជនក្នុងធម្មជាតិ	៥០.០០០	១២.០០០
១១	**កន្លែងកីឬកីឡា**	**៦៣.២០០**	**៤៤.៣០០**
១១.១	កន្លែងហាត់ប្រាណ និងម៉ាសូរ	១៣.០០០	៤.៣០០
១១.២	ទីលានវាយកូនបាល់	២២.០០០	២០.០០០
១១.៣	ទីលានបាល់ទាត់	២៨.២០០	២០.០០០
១២	**តំបន់អភិរក្សព្រៃឈើសំរាប់ដើរលំហែ**	**២៩.៤០០**	
១៣	**លំនៅដ្ឋានក្នុងតំបន់អភិរក្សព្រៃឈើ**	**១៥៣.០០០**	**៤៧.៥០០**
១៣.១	ផ្ទះវីឡាឯកជន និងបឹងកាឡូក្នុងព្រៃធម្មជាតិ	៦៨.១០០	១៨.០០០
១៣.២	ផ្ទះវីឡា	៨៤.៩០០	២៩.៥០០
១៤	**តំបន់ការពារធម្មជាតិ**	**១៧៨.៩០០**	
	ផ្ទៃដីសរុប:	**១.០៧៨.០០០**	**៤៣៩.៦៨៨**

Draft

តំលៃសាងសង់សំរាប់ការអភិវឌ្ឍនៅលើកោះពស់សរុបប្រមាណជា ៣០០ លានដុល្លាអាមេរិកកាំង។



រូបភាព ៣.៣.៣-១: ការរៀបចំប្លង់សមាភាពនៃការអភិវឌ្ឍនៅលើកោះពស់



រូបភាព ៣.៣.៣-២: ការមើលឃើញពីចំហៀងនៃការអភិវឌ្ឍនៅលើកោះពស់

៣.៤ សំភារៈ និងសមាសភាពបំពេញគំរោង

៣.៤.១ តម្រូវការសំភារៈសាងសង់

តម្រូវការសំភារៈសំរាប់សាងសង់រួមមាន:-

- ស៊ីម៉ង់ត៍ នឹងត្រូវបានទិញនៅលើទីផ្សារក្នុងស្រុក
- ដែកសរសៃ និងដែកថែបនឹងត្រូវបានទិញនៅលើទីផ្សារក្នុងស្រុក
- ប្រេងឥន្ធនៈ នឹងត្រូវបានទិញនៅលើទីផ្សារក្នុងស្រុក
- ត្រួស ខ្សាច់ ថ្ម នឹងត្រូវបានទិញនៅលើទីផ្សារក្នុងស្រុក
- សំភារៈដទៃទៀត នឹងត្រូវបាននាំចូលពីបរទេសផង នឹងទិញនៅលើទីផ្សារក្នុងស្រុកផងទៅតាមស្ថានភាពជាក់ស្តែង។

៣.៤.២ ការផ្គត់ផ្គង់ទឹកស្អាត និងថាមពលអគ្គីសនី

គំរោង**មរកត** នឹងប្រើប្រាស់បណ្តាញទឹកស្អាតពីរដ្ឋាករទឹកក្រុងព្រះសីហនុ សំរាប់សកម្មភាពសាងសង់ និងប្រតិបត្តិការគំរោងទាំងស្រុង ដែលមានលិខិតជូនដំណឹង របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីលទ្ធភាពនៃការផ្គត់ផ្គង់ទឹកស្អាតជូនដល់កោះពស់ និងឆ្នេរហាវ៉ៃតាមសំណើរបស់គំរោង (សូមមើលឧបសម្ព័ន្ធទី៥)។ ក្រុមហ៊ុននៅមានដាក់ធុងទឹកចំណុះ ៥m^3 នឹងដាក់បំរុងនៅតាមការដ្ឋានសាងសង់ និងជំរុំកម្មករនៅលើកោះពស់ ការដ្ឋានស្ពាន និងនៅឆ្នេរហាវ៉ៃ។

ក្នុងអំឡុងពេលសាងសង់ថាមពលអគ្គិសនីនឹងផ្គត់ផ្គង់ដោយម៉ាស៊ីនភ្លើងរបស់គំរោងផ្ទាល់ ដែលម៉ាស៊ីនភ្លើងមួយគ្រឿងមានកំលាំង ៣00kW និងពីរគ្រឿងទៀតមានកំលាំង ១៥0kW សំរាប់ម៉ាស៊ីនីមួយ១។ ទោះបីយ៉ាងណាក៏ដោយការប្រើប្រាស់តាមលំនៅដ្ឋាន និងការបំភ្លឺ គឺប្រើប្រាស់បណ្តាញថាមពលអគ្គិសនីពីទីក្រុង។ ប៉ុន្តែអំឡុងពេលប្រតិបត្តិការ គំរោងនឹងប្រើប្រាស់បណ្តាញថាមពលអគ្គិសនីពីទីក្រុងព្រះសីហនុទាំងស្រុង ដែលមានលិខិតជូនដំណឹងរបស់អគ្គិសនីកម្ពុជាស្តីពីលទ្ធភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីជូនដល់កោះពស់ និងឆ្នេរហាវ៉ៃតាមសំណើរបស់គំរោង (សូមមើលឧបសម្ព័ន្ធទី៥)។ ចំណែកម៉ាស៊ីនភ្លើងរបស់ គំរោងផ្ទាល់គឺ ប្រើសំរាប់បំរុងទុកពេលដាច់ចរន្តពីបណ្តាញថាមពលអគ្គិសនីទីក្រុងប៉ុណ្ណោះ។ នៅក្នុងរូបភាពទី ៣.៤.២-១ មានបង្ហាញពីគំនូសបំព្រួញនៃការផ្គត់ផ្គង់ទឹកស្អាត ថាមពលអគ្គិសនី និងសេវាកម្មប្រមូលសំរាមដែលនឹងប្រើប្រាស់សំរាប់គំរោង**មរកត**។

Draft


336000
1180000
1176000
1172000
តំបន់អភិវឌ្ឍន៍ផ្លេសាវ៉ៃ
តំបន់អភិវឌ្ឍន៍ក្រោះពស់
Data Sources
JICA dataset 2002
Projectoin: UTM, Zone 48 N
Ellipsoid: Everest 1830
Datum: India 1960
Unite: Meter
Kilometers

៣.៤.៣ ការគ្រប់គ្រងសំណល់

ក/- សំណល់រឹង

ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនម៉ៅការប្រមូលសំរាម ដើម្បីប្រមូល ដឹកញ្ជូន និងយកទៅបោះចោលនូវសំណល់រឹងគ្រប់ប្រភេទចេញពីតំបន់អភិវឌ្ឍន៍ទាំងមូល ដែលសព្វថ្ងៃនេះក្រុមហ៊ុនកោះពស់មានកិច្ចសន្យាជាមួយក្រុមហ៊ុន CINTRI ដើម្បីប្រមូលសំណល់/សំរាមចេញពីការិយាល័យ និងលំនៅដ្ឋានរបស់ក្រុមហ៊ុន (សូមមើលឧបសម្ព័ន្ធទី៥)។ មានន័យថា នៅពេញរយៈពេលដំណើរការគំរោងទាំងមូលឧបករណ៍និងសំភារៈប្រមូលសំរាមនឹងមានដាក់នៅគ្រប់ទីតាំងអភិវឌ្ឍន៍របស់គំរោងដើម្បីប្រមូលយកសំណល់រឹងទាំងអស់ជាប្រចាំ និងដឹកជញ្ជូនយ៉ាងត្រឹមត្រូវយកទៅបោះចោលនៅកន្លែងចាក់សំរាមដែលមានការអនុញ្ញាតដោយអាជ្ញាធរខេត្តព្រះសីហនុ។

ខ/- សំណល់រាវ ឬទឹកក្រខ្វក់

សមាសភាពគំរោង**មរកត** ស្ទើរតែទាំងអស់សុទ្ធតែការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ដូចជា ឆ្នេរ សណ្ឋាគារ កាស៊ីណូ ទីលានវាយកូនហ្គោល និងកន្លែងសំរាកកាយ ដូចនេះការការពារបរិស្ថានទៅលើធនធានធម្មជាតិក្នុងតំបន់គំរោងគឺជាប្រធានបទយ៉ាងសំខាន់សំរាប់ការរៀបចំរចនាប្លង់។ ឧទាហរណ៍ជាក់ស្តែង ដើម្បីថែទាំគុណភាពទឹក និងភាពស្អាតនៃឆ្នេរ នោះក្រុមហ៊ុនកោះពស់បានរៀបចំបំពាក់អាងធ្វើប្រព្រឹត្តិកម្មសំអាតទឹកក្រខ្វក់ ហៅកាត់ជាភាសាអង់គ្លេសថា (WWTP) ទាំងនៅលើ ទីតាំងអភិវឌ្ឍកោះពស់ និងនៅលើទីតាំងអភិវឌ្ឍឆ្នេរហាវ៉ៃ។

<u>**ខ១/-អាងធ្វើប្រព្រឹត្តិកម្មសំអាតទឹកក្រខ្វក់នៅលើកោះពស់**</u>

សមត្ថភាពនៃ WWTP នៅលើកោះពស់អាចប្រមូលយកទឹកក្រខ្វក់ចេញពីតំបន់លំនៅដ្ឋាន តំបន់ពាណិជ្ជកម្ម តំបន់កំសាន្ត សណ្ឋាគារ ភោជនីយដ្ឋាន និងអាគាររដ្ឋាភិបាលនៅលើកោះពស់ទាំងអស់។ មាន WWTP ចំនួនបួនដែលបានរៀបចំសមត្ថភាពផ្សេងៗគ្នា តាមទីតាំងសមស្របលើកោះ ដើម្បីគិតគូរដល់លំហូរសេរីក្នុងការប្រមូលយកទឹកក្រខ្វក់ ដូចមានបង្ហាញជូនក្នុងតារាង ៣.៤.៣-១ និងរូបភាព ៣.៤.៣-១។

ទឹកដែលធ្វើការសំអាតរួច នឹងបង្ហូរតាមបំពង់ដែលមានទំហំ ២៥០-៤៥០មម និងមានចំងាយរាប់រយម៉ែត្រពីឆ្នេរចូលទៅក្នុងសមុទ្រ។ ចំណែកកំរិតតំលៃនៃប៉ារ៉ាម៉ែត្រសំខាន់ៗដែលបង្ហូរចេញពី WWTP ទាំងពីរទីតាំងអភិវឌ្ឍលើកោះពស់ និងលើឆ្នេរហាវ៉ៃ មានរៀបរាប់នៅក្នុងតារាង ៣.៤.៣-២។ លក្ខណៈទូទៅនៃអាងធ្វើប្រព្រឹត្តិកម្មសំអាតទឹកក្រខ្វក់នៅលើកោះពស់មានបង្ហាញនៅរូបភាព ៣.៤.៣-២

តារាង ៣.៤.៣-១: សមត្ថភាព WWTP នីមួយៗនៅលើកោះពស់

ឈ្មោះ	អត្រាលំហូរ.គិតជា ម^{3}/ថ្ងៃ
WWTP 1	១.១៩៨
WWTP 2	២.៣៣៣
WWTP 3	១.៣៥៧
WWTP 4	៤.៤៤0
សរុប	**៩.៣២៨**



Draft

រូបភាព ៣.៤.៣-១: ការរៀបចំទីតាំង WWTP នៅលើកោះពស់

តារាង ៣.៤.៣-២: ការរៀបចំតំលៃនៃការបង្ហូរចេញ

ល.រ	ប៉ារ៉ាម៉ែត្រ	កំរិតតំលៃនៃការបង្ហូរចេញ. ម.ក្រ/ល
១	តំរូវការអុកស៊ីសែនសំរាប់គីមីជីវៈ (BOD_5)	<២0
២	អង្គធាតុរឹងអណ្តែត (SS)	<៣0
៣	សំណល់ជាតិក្លរ	<១


C
B
A

ខ២/-អាងធ្វើប្រព្រឹត្តិកម្មសំអាតទឹកក្រខ្វក់នៅលើឆ្នេរហាវ៉ៃ

សមត្ថភាពនៃ WWTP នៅលើឆ្នេរហាវ៉ៃអាចប្រមូលយកទឹកក្រខ្វក់ចេញពីតំបន់អភិវឌ្ឍទាំងមូល។ តាមផែនការមេមាន WWTP ចំនួនពីរដែលបានរៀបចំសមត្ថភាពផ្សេងៗគ្នា ដាក់តាមទីតាំងសមស្របដូចមានបង្ហាញជូនក្នុងតារាង ៣.៤.៣-៣ និងរូបភាព ៣.៤.៣-៣។ លក្ខណៈទូទៅនៃប្រភេទ WWTP នៅលើឆ្នេរហាវ៉ៃមានបង្ហាញជូននៅរូបភាព ៣.៤.៣-៤។

តារាង ៣.៤.៣-៣: សមត្ថភាព WWTP នីមួយៗនៅលើឆ្នេរហាវ៉ៃ

ឈ្មោះ	អត្រាលំហូរ.គិតជា ម^{3}/ថ្ងៃ
WWTP 1	២.៥៩១
WWTP 2	៣.000
សរុប	៥.៥៩១



Draft

រូបភាព ៣.៤.៣-៣: ការរៀបចំទីតាំង WWTP នៅលើឆ្នេរហាវ៉ៃ



Draft

គ/- ប្រព័ន្ធរំដោះទឹក

ប្រព័ន្ធរំដោះទឹកដែលបានរៀបចំដោយគំរោងនៅលើទីតាំងអភិវឌ្ឍទាំងពីរគឺ នៅលើកោះពស់ និងលើឆ្នេរ ហាវ៉ៃ មាននៅក្នុងការរចនាបង្ហាញលំអិត។ ក្នុងរូបភាព ៣.៤.៣-៥ មានបង្ហាញជូននូវ លក្ខណៈទូទៅនៃប្រព័ន្ធរំដោះទឹករបស់គំរោងមរកត។



Draft

រូបភាព ៣.៤.៣-៥: លក្ខណៈទូទៅនៃប្រព័ន្ធរំដោះទឹករបស់គំរោងមរកត

ជាងនេះទៀតនោះ ការដាក់បំពង់លូតាមបណ្តោយផ្លូវពីរធ្ជ ដែលប្រើជាប្រព័ន្ធរំដោះទឹកនៃឆ្នេរហាវ៉ៃត្រូវបានអនុម័តយល់ព្រមដោយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុរួចហើយដែរ (សូមមើលឧបសម្ព័ន្ធទី៥)។

៣.៤.៤ តំរូវការកំលាំងពលកម្ម

ការងារសាងសង់នឹងត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនម៉ៅការសំណង់ក្នុងស្រុក និងក្រៅស្រុកតាមការជ្រើសរើសរបស់ម្ចាស់គំរោងជាធម្មតា។ តែទោះបីជា ក្រុមហ៊ុនម៉ៅការសំណង់មកពីក្រៅប្រទេស ក៏កម្មករជំនាញមួយចំនួន និងកំលាំងពលកម្មនៃអ្នកម៉ៅការផ្ទាល់ និងអ្នកម៉ៅការបន្ទាប់គឺជាប្រជាជនក្នុងស្រុក ឬក្នុងមូលដ្ឋាន។ យ៉ាងណាក៏ដោយ គំរោងមរកតគឺមានបំណងជ្រើសយកពលករដែលរស់នៅជុំវិញទីតាំងគំរោង។ ចំនួននៃតំរូវការពលករសំរាប់គំរោងទាំងមូលមានរៀបរាប់នៅក្នុងតារាង ៣.៤.៤-១។

តារាង ៣.៤.៤-១: តំរូវការពលករសំរាប់គំរោង**មរកត**

ល.រ	បរិយាយ	ប្រភេទបុគ្គលិក	អំឡុងពេលសាងសង់ . នាក់	អំឡុងពេលដំណើរការ . នាក់
១	ស្ពាន			
		- បុគ្គលិករដ្ឋបាល និងអ្នកគ្រប់គ្រង	២៥	៥
		- វិស្វករ	១០-២០	១
		- កម្មករ	៧០-១៥០	៥
២	ឆ្នេរហាវ៉ៃ			
		- បុគ្គលិករដ្ឋបាល និងអ្នកគ្រប់គ្រង	១០	១៥
		- វិស្វករ	១០	១០
		- កម្មករ	២០០	១០០
៣	កោះពស់			
		- បុគ្គលិករដ្ឋបាល និងអ្នកគ្រប់គ្រង	៤០	១០០
	.	- វិស្វករ	៥០	៤០
		- កម្មករ	៥០០	១២០០
	សរុប		**៩៩៥**	**១៤៧៦**

Draft

៣.៥ ក្រោងពេលវេលាសំរាប់អនុវត្តន៍គំរោង

ពេលវេលាសំរាប់អនុវត្តន៍គំរោងគឺ បានគ្រោងដូចតទៅ:-

- ការងារសាងសង់ស្ពាន: ២០០៨-២០១០ (៣ឆ្នាំ)
- ការអភិវឌ្ឍផ្លូវហាវ៉ៃ: ២០០៩-២០១២ (៤ឆ្នាំ)
- ការអភិវឌ្ឍលើកោះពស់: ២០១០-២០១៥ (៦ឆ្នាំ)

តារាង ៣.៥-១: ក្រោងពេលវេលា សំរាប់អនុវត្តន៍សមាសភាពនីមួយៗរបស់គំរោង

ឈ្មោះគំរោង		ចាប់ផ្តើមគំរោង	បញ្ចប់គំរោង
គំរោងមរកត		វិច្ឆិកា ២០០៧	ធ្នូ ២០១៥
តំបន់		រយៈពេលសាងសង់	
១	សាងសង់ស្ពានចំងាយ ៩០០ម	៣៣ ខែ	
២	សាងសង់នៅតំបន់ផ្លូវខ្សាច់	៥៨ ខែ	
៣	តំបន់កំសាន្តក្បែរផ្លូវខ្សាច់	៧២ ខែ	
៤	តំបន់វប្បធម៌	៤៨ ខែ	
៥	តំបន់លំនៅដ្ឋានកំរិតខ្ពស់	៣៨ ខែ	
៦	ទូលខ្ពស់មើលឃើញជុំវិញកោះ និងរូបបដិមាមួយអង្គ	៣៤ ខែ	
៧	តំបន់ល្បែង/កាស៊ីណូ	៥០ ខែ	
៨	មជ្ឈមណ្ឌលលក់ទំនិញ	៣៦ ខែ	
៩	តំបន់អាគារលំនៅដ្ឋានបែបទីក្រុង នៅក្បែរស្ពាន	៤៨ ខែ	
១០	តំបន់លំនៅដ្ឋានក្នុងធម្មជាតិ	៤៦ ខែ	
១១	តំបន់ក្លីបកីឡា	៣៦ ខែ	
១២	តំបន់អភិរក្សព្រៃឈើសំរាប់ដើរលំហែ	៤៥ ខែ	
១៣	លំនៅដ្ឋានក្នុងតំបន់អភិរក្សព្រៃឈើ	៦០ ខែ	
១៤	តំបន់បំរើឱ្យសេវាកម្មសាធារណៈ	-	
១៥	ផ្ទាល់	៧០ ខែ	
A	ផ្លូវហាវ៉ៃ	៣៦ ខែ	
B	កន្លែងលើដីគោជាប់គល់ស្ពាន	៤៥ ខែ	

Draft